


SEA-PLM

វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍

# របាយការណ៍ថ្នាក់ជាតិ

## ស្តីពី

## វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិត បឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ ឆ្នាំ២០២៤ ( SEA-PLM 2024) របស់កម្ពុជា



# មាតិកា

ផ្នែកទី១៖ ទិដ្ឋភាពទូទៅ

ផ្នែកទី២៖ លទ្ធផលសិក្សារបស់សិស្ស

ផ្នែកទី៣៖ កត្តាសំខាន់ៗរួមចំណែកដល់លទ្ធផលរបស់សិស្ស

ផ្នែកទី៤៖ ភាពជាពលរដ្ឋសកល

ផ្នែកទី៥៖ វិធានការលើកកម្ពស់មូលដ្ឋានគ្រឹះនៃការសិក្សា

SEA-PLM



# ផ្នែកទី១៖ ទិដ្ឋភាពទូទៅ

១. គោលបំណងនៃការវាយតម្លៃ SEA-PLM

២. វិធីសាស្ត្រវាយតម្លៃ



# ១. ទិដ្ឋភាពទូទៅវាយតម្លៃ SEA-PLM

- វាស់វែងលទ្ធផលការសិក្សារបស់សិស្សថ្នាក់ទី ៥ លើចំណេះដឹងផ្នែក អំណាន សំណេរ គណិតវិទ្យា និងភាពជាពលរដ្ឋសកល។
- ជារង្វាយតម្លៃកម្រិតតំបន់ និងជាកម្មវិធីពង្រឹងសមត្ថភាពរបស់ប្រព័ន្ធអប់រំនៃប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលស្ម័គ្រចិត្តចូលរួមជាផ្លូវការ ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស និងលើកកម្ពស់សមធម៌នៃការទទួលបានមូលដ្ឋានគ្រឹះនៃការអប់រំ។
- ផ្តល់ជាតុចូលសម្រាប់កែទម្រង់កម្រិតគោលនយោបាយ និងកែលម្អប្រសិទ្ធភាពក្នុងការបង្រៀន និងការរៀន ដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាសមត្ថភាពរបស់ប្រព័ន្ធអប់រំក្នុងការផ្តល់ឱកាសរៀនសូត្របន្ថែមទៀតដល់សិស្សនាពេលបច្ចុប្បន្ន និងអនាគត។








# ១. ទិដ្ឋភាពទូទៅរង្វាយតម្លៃ SEA-PLM

## គោលបំណងនៃរង្វាយតម្លៃ SEA-PLM

- ពង្រឹងសមត្ថភាពរៀបចំ និងវិភាគទិន្នន័យរង្វាយតម្លៃលទ្ធផលសិក្សានៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ពង្រឹងសមត្ថភាពប្រើប្រាស់ទិន្នន័យរង្វាយតម្លៃ ដើម្បីកែលម្អប្រព័ន្ធអប់រំ និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សប្រកបដោយសមធម៌នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ជំរុញការធ្វើសមាហរណកម្មវិធីសាស្ត្រវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្សក្នុងតំបន់អាស៊ាន ដោយផ្តោតលើសមត្ថភាពរបស់សិស្សបឋមសិក្សាថ្នាក់ទី៥ លើអំណាន សំណេរ គណិតវិទ្យា និងភាពជាពលរដ្ឋសកល។

# ២. វិធីសាស្ត្រវាយតម្លៃ

## ការជ្រើសរើសសំណាក និងការប្រមូលទិន្នន័យ

- ការជ្រើសរើសសំណាកត្រូវអនុវត្តតាមពីរដំណាក់កាល (Two-stage sampling process)។
  - ទី១៖ ជ្រើសរើសសាលារៀន ដោយប្រើប្រាស់វិធីសាស្ត្រចៃដន្យជាប្រព័ន្ធ (Systematic random sampling)។
  - ទី២៖ ជ្រើសរើស១ថ្នាក់ ដោយចៃដន្យ ក្នុងចំណោមថ្នាក់ទី៥ សរុបក្នុងសាលារៀនសំណាកនីមួយៗ ហើយសិស្សទាំងអស់នៅក្នុងថ្នាក់រៀនដែលបានជ្រើសរើសនោះត្រូវចូលរួមក្នុងការវាយតម្លៃ។
- ចំនួនសំណាកនៅក្នុងឆ្នាំ២០១៩ និង២០២៤

| វគ្គ | ចំនួនសំណាក | | | | |
|---|---|---|---|---|---|
| | សាលារៀន | ថ្នាក់រៀន | គ្រូបង្រៀន | សិស្ស | មាតាបិតា |
| SEA-PLM ឆ្នាំ២០២៤ | 195 | 195 | 196 | 6,574 | 6,574 |
| SEA-PLM ឆ្នាំ២០១៩ | 177 | 177 | 380 | 5,396 | 5,374 |



# ២. វិធីសាស្ត្រវាយតម្លៃ

- ឧបករណ៍ប្រមូលទិន្នន័យ៖
  - សៀវភៅតេស្ត៖ ១៨ ក្បាលផ្សេងគ្នា
  - កម្រងសំណួរ៖ សាលារៀន សិស្ស មាតាបិតាសិស្ស និងគ្រូបង្រៀន។
- ការប្រមូលទិន្នន័យបានធ្វើឡើងនៅក្នុងអំឡុងខែសីហា ឆ្នាំ២០២៤
- ចំនួនសាលារៀនតាមទីតាំងភូមិសាស្ត្រ

| វដ្ត | ទីតាំងភូមិសាស្ត្រ | | | | | សរុប |
|---|---|---|---|---|---|---|
| | ភ្នំពេញ | ទំនាប | បឹងទន្លេសាប | ខ្ពង់រាប | មាត់សមុទ្រ | |
| SEA-PLM ឆ្នាំ២០២៤ | 17 (9%) | 56 (29%) | 54 (28%) | 49 (25%) | 19 (10%) | 195 |
| SEA-PLM ឆ្នាំ២០១៩ | 14 (8%) | 64 (36%) | 58 (33 %) | 29 (16%) | 12 (7%) | 177 |

- ចំនួនសាលារៀនតាមតំបន់

| វដ្ត | តំបន់ | | សរុប |
|---|---|---|---|
| | ប្រជុំជន | ជនបទ | |
| SEA-PLM ឆ្នាំ២០២៤ | 67 ( 34% ) | 128 ( 66% ) | 195 |
| SEA-PLM ឆ្នាំ២០១៩ | 35 ( 20% ) | 142 (  80% ) | 177 |



# ២. វិធីសាស្ត្រវាយតម្លៃ

## ពិន្ទុ និងកម្រិតសមត្ថភាពនៃ SEA-PLM

- លទ្ធផលនៃការសិក្សារបស់សិស្សត្រូវបានបង្ហាញជាពីរទម្រង់គឺ មាត្រដ្ឋានពិន្ទុ (Scale Scores) និង មាត្រដ្ឋានសមត្ថភាព (Proficiency Scales)
- មាត្រដ្ឋានពិន្ទុ (Scale Scores)
- មាត្រដ្ឋានសមត្ថភាពផ្នែកអំណាន (Proficiency Scale) ត្រូវបានបែងចែកជា ៥ Bands៖
  - បើសិស្សនៅកម្រិត៣ ចុះក្រោម ត្រូវបានចាត់ទុកថាសិស្សខ្សោយ និងសិស្សនៅកម្រិតចាប់ពី ៥ ឡើងជាសិស្សពូកែ
- មាត្រដ្ឋានសមត្ថភាពផ្នែកគណិតវិទ្យា (Proficiency Scales) ត្រូវបានបែងចែកជា ៨ Bands៖
  - បើសិស្សនៅកម្រិត៣ ចុះក្រោម ត្រូវបានចាត់ទុកថាសិស្សខ្សោយ និងសិស្សនៅកម្រិតចាប់ពី ៥ ឡើងជាសិស្សពូកែ



# ២.វិធីសាស្ត្រវាយតម្លៃ

## មាត្រដ្ឋាន និងសេចក្ដីពិពណ៌នាលើផ្នែកអំណាន របស់វង្វាយតម្លៃ SEA-PLM

| កម្រិតសមត្ថភាព | សេចក្ដីពិពណ៌នាអំពីសមត្ថភាពសិស្សអាចធ្វើបាន |
|---|---|
| កម្រិត៦ និងខ្ពស់ជាង៖ ពិន្ទុ៣១៧ និងខ្ពស់ជាង (១៨.៤%) | **យល់អត្ថបទដោយស៊ាំនឹងរចនាសម្ព័ន្ធក្នុងអត្ថបទ និងយល់ដឹងពីព័ត៌មានស្មុគស្មាញផ្សេងៗ**<br>សិស្សយល់ពីអត្ថបទដោយស៊ាំនឹងរចនាសម្ព័ន្ធក្នុងអត្ថបទ និងយល់ដឹងពីព័ត៌មានស្មុគស្មាញផ្សេងៗនៅពេលកំណត់រកគំនិតសំខាន់ៗ និងព័ត៌មានលម្អិតក្នុងអត្ថបទ។ សិស្សស្វែងរកបណ្ដុំព័ត៌មានដែលមានទំនាក់ទំនងគ្នាក្នុងរចនាសម្ព័ន្ធអត្ថបទបានយ៉ាងងាយស្រួល និងផ្សារភ្ជាប់ព័ត៌មានលម្អិតជាមួយនឹងគំនិតផ្សេងៗដើម្បីទាញរកសេចក្ដីសន្និដ្ឋាន។ សិស្សប្រើប្រាស់តម្រុយ និងព័ត៌មានច្បាស់លាស់ងាយយល់ដើម្បីគាំទ្រសេចក្ដីសន្និដ្ឋាន នៅពេលបំពេញព័ត៌មាន។ សិស្សកំណត់បានហេតុផលជាក់លាក់ភាគច្រើនសម្រាប់ពន្យល់លើព្រឹត្តិការណ៍ណាមួយ និងប្រតិកម្មឆ្លើយតបរបស់តួអង្គក្នុងការរៀបរាប់ពីដំណើររឿងដែលព័ត៌មានទាំងនោះអាចប្រើបានចំពោះខ្លឹមសារក្នុងអត្ថបទតែប៉ុណ្ណោះ។ |
| កម្រិត៥៖ ពិន្ទុ៣០៤ ដល់ ៣១៦ ដល់ (២០.៥%) | **ភ្ជាប់ព័ត៌មានដែលមានទំនាក់ទំនងគ្នាដើម្បីយល់ពីគំនិតសំខាន់ៗ**<br>សិស្សផ្សារភ្ជាប់ទំនាក់ទំនងបណ្ដុំព័ត៌មានដែលទាក់ទងគ្នាក្នុងផ្នែកផ្សេងៗនៃអត្ថបទ ដូចជាតារាង និងដ្យាក្រាមជាដើម ដើម្បីស្វែងយល់ពីគំនិតសំខាន់ៗ។ បរិបទ និងគំនិតក្នុងអត្ថបទដែលសិស្សបានជួប អាចមិនស៊ាំទាំងស្រុងដល់សិស្សទេ។ សិស្សស្គាល់ឃ្លា និងល្បះមួយចំនួនដែលមានអត្ថន័យដូចគ្នា ហើយទាញការសន្និដ្ឋានបែបសាមញ្ញនៅពេលជួបព័ត៌មានស្មុគស្មាញមួយចំនួន។ សិស្សកំណត់បានពីគោលបំណងនៃលក្ខណៈអត្ថបទខ្លីៗធ្លាប់ជួប ហើយអាចប្រើប្រាស់លក្ខណៈនៃអត្ថបទទាំងនោះដើម្បីរកព័ត៌មាន។ |



# ២. វិធីសាស្ត្រវាយតម្លៃ

| កម្រិតសមត្ថភាព | សេចក្ដីពិពណ៌នាអំពីសមត្ថភាពសិស្សអាចធ្វើបាន |
|---|---|
| កម្រិត៤៖<br>ពិន្ទុ ២៨៩ ដល់ ៣០៣ ដល់<br>(២៤.៤%) | **យល់បានអត្ថបទសាមញ្ញៗ**<br>សិស្សអាចយល់បានអត្ថបទសាមញ្ញៗដែលមានគំនិត និងមានព័ត៌មានមួយចំនួនដែលសិស្សមិនធ្លាប់ជួបពីមុន។ សិស្សកំណត់បានទស្សនៈខ្លីៗមួយចំនួនដែលមានអត្ថន័យដូចគ្នា (ឧទា. ន័យដូចគ្នា) ហើយប្រើប្រាស់លក្ខណៈនៃអត្ថបទនេះដើម្បីកំណត់រកព័ត៌មានក្នុងតារាង និងក្នុងប្រភេទអត្ថបទដែលធ្លាប់ជួបដទៃផ្សេងទៀត។ សិស្សភ្ជាប់ព័ត៌មានសំខាន់ៗក្នុងប្រយោគដែលនៅជាប់គ្នា។ សិស្សទាញសេចក្ដីសន្និដ្ឋានបាន នៅពេលមានតម្រុយច្បាស់លាស់ក្នុងអត្ថបទសាមញ្ញៗ។ សិស្សបកស្រាយព័ត៌មានតាមរយៈហេតុផលដែលមាននៅក្នុងអត្ថបទ និងអាចកំណត់ពីគោលបំណងនៃប្រភេទអត្ថបទងាយៗ។<br>ក្នុងការផ្គូផ្គងពាក្យទៅនឹងរូបភាព សិស្សជ្រើសរើសរវាងពាក្យដែលស្រដៀងគ្នា ប៉ុន្តែមានអត្ថន័យខុសគ្នា និងអាចកំណត់បានប្រយោគវែងដែលពណ៌នាអំពីរូបភាពនោះ។ |
| កម្រិត៣៖<br>ពិន្ទុ ២៧៤ ដល់ ២៨៨<br>(១៩.៩%) | **អានអត្ថបទប្រចាំថ្ងៃជាច្រើនបានយ៉ាងស្ទាត់ និងចាប់ផ្ដើមយល់ន័យក្នុងអត្ថបទទាំងនោះ**<br>សិស្សអាចអានអត្ថបទប្រចាំថ្ងៃបានជាច្រើន ដូចជាអត្ថបទរឿងនិទាន និងទស្សនៈផ្ទាល់ខ្លួន ហើយចាប់ផ្ដើមយល់អត្ថន័យក្នុងអត្ថបទ។ សិស្សរកព័ត៌មានលម្អិតសំខាន់ៗក្នុងអត្ថបទប្រចាំថ្ងៃ ព្រមទាំងភ្ជាប់នឹងខ្លឹមសារ/ព័ត៌មានសាមញ្ញៗ ដែលទាក់ទងគ្នា និងដែលអាចធ្វើឱ្យប្រឡំតិចតួច។ សិស្សធ្វើសេចក្ដីសន្និដ្ឋានសាមញ្ញៗតាមរយៈព័ត៌មានក្នុងអត្ថបទ។ |



# ២. វិធីសាស្ត្រវាយតម្លៃ

| កម្រិតសមត្ថភាព | សេចក្តីពិពណ៌នាអំពីសមត្ថភាពសិស្សអាចធ្វើបាន |
|---|---|
| កម្រិត២ និងក្រោម ២៖ ទាបជាងពិន្ទុ ២៧៤ (១៦.៩%) | **កំណត់បានពីទំនាក់ទំនងរវាងពាក្យ និងអត្ថន័យរបស់ពាក្យ**<br>មានសំណួរតេស្តតិចតួចប៉ុណ្ណោះនៅក្នុងរង្វាយតម្លៃ SEA-PLM ដែលទាបជាងកម្រិតសមត្ថភាពទី៣ ដូច្នេះគេមិនអាចបង្កើតសេចក្តីពណ៌នាជាទូទៅសម្រាប់សិស្សស្ថិតក្នុងសមត្ថភាពទាបជាងកម្រិតទី៣ លើផ្នែកអំណានបានទេ។ ទោះបីជាយ៉ាងនេះក៏ដោយ សំណួរតេស្តដែលបានបង្ហាញថា សិស្សមានសមត្ថភាពកម្រិត២ និងអាចនៅក្រោមកម្រិត២ ជាទូទៅ អាចផ្គូផ្គងពាក្យ១ ក្នុងចំណោមពាក្យចំនួន៤ ទៅនឹងរូបភាពវត្ថុទីកន្លែង និងនិមិត្តសញ្ញាដែលជាកិច្ចការសាមញ្ញត្រង់ៗ និងដដែលៗ។ នេះបង្ហាញថា សិស្សដែលស្ថិតទាបជាងកម្រិតទី៣ ខាងលើ អាចយល់បានអត្ថន័យរបស់ពាក្យ។ |



# ២. វិធីសាស្ត្រវាយតម្លៃ

## មាត្រដ្ឋាន និងសេចក្តីពិពណ៌នាលើផ្នែកគណិតវិទ្យា របស់រង្វាយតម្លៃ SEA-PLM

| កម្រិតសមត្ថភាព | សេចក្តីពិពណ៌នាអំពីសមត្ថភាពសិស្សអាចធ្វើបាន |
|---|---|
| កម្រិត៩ និងខ្ពស់ជាង៩៖ ពិន្ទុ ៣៤៧ និងខ្ពស់ជាង (១.៦%) | មានសំណួរតេស្តតិចតួចសម្រាប់ពណ៌នាសមត្ថភាពសិស្សដែលអាចបំពេញបាននៅក្នុងកម្រិតខ្ពស់ជាងកម្រិត៨។ ទោះបីយ៉ាងណាក៏ដោយ សំណួរតេស្តដែលបង្ហាញថាសិស្សនៅកម្រិត៩ និងខ្ពស់ជាងនេះ អាចទាញហេតុផលអំពីត្រីកោណដើម្បីរកប្រវែងជ្រុងដែលមិនស្គាល់ ដោយប្រើប្រាស់ព័ត៌មានអំពីបរិមាត្រ និងសិស្សអាចដោះស្រាយចំណោទដោយប្រើប្រាស់បំណែងចែកប្រេកង់។ |
| កម្រិត៨៖ ពិន្ទុ ៣៣៥ ដល់ ៣៤៦ (៥.២%) | **គិតពិចារណាលើប្រមាណវិធីគុណ បំប្លែងខ្នាត**<br><br>សិស្សអាចដោះស្រាយចំណោទដោយប្រើប្រាស់ប្រមាណវិធីបូកប្រភាគដែលមានភាគបែងដូចគ្នា និងដោយប្រមាណវិធីចែកចំនួនទសភាគនឹងចំនួនគត់១ ខ្ទង់។ សិស្សអាចបំពេញលំនាំគំរូជាចំនួនទសភាគ។ សិស្សអាចបំលែងសំណល់នៃម៉ោងទៅជានាទី និងសិស្សអាចគណនាពីភាពខុសគ្នារវាងប្រវែងដែលត្រូវការប្តូរខ្នាត។ សិស្សអាចដោះស្រាយចំណោទដោយប្រើប្រាស់ក្រាបរូបភាពពីមួយទៅច្រើន។ |
| កម្រិត៧៖ ពិន្ទុ ៣២២ ដល់ ៣៣៤ (១២.៧%) | **អនុវត្តប្រភាគនិងភាគរយ និងវិភាគការតាងទិន្នន័យ**<br><br>សិស្សអាចគណនាភាគរយនិងប្រភាគងាយនៃមួយចំនួន។ សិស្សអាចកំណត់បានពីរង្វិលកន្លះជុំនៃរូបគំរូ។ សិស្សអាចរកតម្លៃមិនស្គាល់នៅក្នុងតារាងដោយប្រើប្រាស់តម្លៃសរុប និងគណនាតម្លៃភាគរយដែលមិនស្គាល់នៅលើក្រាបផ្ចិត។ |

# ២. វិធីសាស្រ្តវាយតម្លៃ

| កម្រិតសមត្ថភាព | សេចក្តីពិពណ៌នាអំពីសមត្ថភាពសិស្សអាចធ្វើបាន |
|---|---|
| កម្រិត៦៖<br>ពិន្ទុ ៣០៩ ដល់ ៣២១<br>(២០.៣%) | **អនុវត្តប្រមាណវិធីគណិតវិទ្យាលើប្រភាគ និងបកស្រាយតារាងនិងក្រាប**<br>សិស្សអាចបំលែងប្រភាគមានភាគបែងតូចជាង ១០ ទៅជាចំនួនទសភាគ។ សិស្សស្គាល់តម្លៃខ្ទង់ និងបង្គត់ចំនួនទសភាគដែលមានផ្នែកទសភាគរហូតដល់ ៥ ខ្ទង់។ សិស្សអាចដោះស្រាយចំណោទទាក់ទងនឹងឧបករណ៍រង្វាស់រង្វាល់ដែលត្រូវការបំលែងខ្នាតប្រវែង និងខ្នាតចំណុះ។ សិស្សអាចគណនាទម្ងន់នៃវត្ថុដោយប្រើប្រាស់ជញ្ជីង។<br>សិស្សអាចបូក ៣០ នាទី បន្ថែមលើពេលវេលាដែលគេឱ្យ។ សិស្សអាចចង្អុលបង្ហាញវត្ថុដែលមានវិមាត្រ៣ ចេញពីរូបតំណាងជារូបធរណីមាត្រវិមាត្រ ២ និងបកស្រាយផែនទីងាយៗ ដោយប្រើប្រាស់ភាសាបញ្ជាក់ទិសដៅ។ សិស្សបកស្រាយតារាងប្រេកង់ និងក្រាបខ្សែដែលបង្ហាញពីកំណើនតាមពេល។ |
| កម្រិត៥៖<br>ពិន្ទុ ២៩៦ ដល់ ៣០៨<br>(២២.៣%) | **ដោះស្រាយចំណោទដោយប្រើប្រាស់ប្រមាណវិធីនព្វន្តយ៉ាងស្ទាត់ជំនាញ**<br>សិស្សអាចធ្វើប្រមាណវិធីបូកចំនួនគត់ដែលមានលេខ ៤ខ្ទង់ និងប្រមាណវិធីដកចំនួនគត់ដែលមានលេខ ២ខ្ទង់នៅក្នុងបរិបទប្រចាំថ្ងៃ ហើយសិស្សអាចកំណត់ចំនួនគត់ដែលមានលេខ ៥ខ្ទង់ បានតាមរយៈពាក្យអានចំនួនដែលគេឱ្យ។ សិស្សអាចរាប់ចំនួនងាយៗបន្តក្នុងលំនាំគំរូលេខ។ សិស្សអាចបំពេញលំនាំគំរូតាមរាងធរណីមាត្រ។ សិស្សអាចបង្កើតវិធានដោះស្រាយចំណោទដោយប្រើប្រាស់ប្រមាណវិធីគុណនិងចែក។ សិស្សយល់ពីលំនាំនៃការកំណត់តម្លៃពាក់កណ្តាលនៃបរិមាណមួយ។ សិស្សអាចប៉ាន់ស្មានចំណុះចេញពីស៊ីឡាំងក្រិត និងអាចប្រៀបធៀបមុំធៀបនឹងមុំកែង។ សិស្សអាចប៉ាន់ស្មានទម្ងន់នៃវត្ថុ។ សិស្សអាចអានចំនួននៅក្នុងតារាង និងផលបូកនៃចំនួនទាំងនោះដែលនៅក្នុងតារាង។ សិស្សយល់ពីសំណង់នៃក្រាបសសរដែលបង្ហាញបរិមាណតាមពេល។ |



# ២.វិធីសាស្ត្រវាយតម្លៃ

| កម្រិតសមត្ថភាព | សេចក្ដីពិពណ៌នាអំពីសមត្ថភាពសិស្សអាចធ្វើបាន |
|---|---|
| កម្រិត៤៖<br>ពិន្ទុ ២៨៣ ដល់ ២៩៥<br>(១៨.៤%) | **អនុវត្តលក្ខណៈចំនួន និងខ្នាតរង្វាស់រង្វាល់**<br>សិស្សអាចរកតម្លៃពាក់កណ្ដាលនៃចំនួនគត់គូដែលមានលេខ ១ខ្ទង់ និងយល់ច្បាស់ពីតម្លៃខ្ទង់នៃចំនួនទសភាគដែលមានផ្នែកទសភាគ ៥ខ្ទង់។ សិស្សអាចដោះស្រាយចំណោទទាក់ទងនឹងចំណុះដែលមិនត្រូវការប្ដូរខ្នាត។ សិស្សប្រើប្រាស់ចំណេះដឹងរបស់ពួកគេអំពីចំនួននាទីក្នុងមួយម៉ោង។ សិស្សអាចអានតម្លៃលេខលើក្រាបសសរ។ |
| កម្រិត៣៖<br>ពិន្ទុ ២៦៩ ដល់ ២៨២<br>(១១.៧%) | **យល់ច្បាស់ពីតម្លៃខ្ទង់ និងទំហំនៃរង្វាស់រង្វាល់**<br>សិស្សអាចរៀបលំដាប់ចំនួនគត់ដែលមានលេខ ២ខ្ទង់។ សិស្សអាចអានតម្លៃប្រវែង និងរង្វាស់ទម្ងន់លើឧបករណ៍រង្វាស់រង្វាល់ ដែលត្រូវការប៉ាន់ស្មានមួយចំនួន។ សិស្សអាចស្គាល់រូបធរណីមាត្រងាយៗ និងប្រៀបធៀបមុំ។ សិស្សអាចបកស្រាយក្រាបសសរងាយៗ។ |
| កម្រិត២ និងក្រោម ២៖<br>ទាបជាងពិន្ទុ ២៦៩<br>(៧.៩%) | មានសំណួរតេស្តតិចតួចសម្រាប់ពណ៌នាសមត្ថភាពសិស្សអាចដែលបំពេញបាននៅកម្រិតទាបជាងកម្រិត ៣។ សិស្សមួយចំនួនគួរតែមានសមត្ថភាពធ្វើប្រមាណវិធីបូកចំនួនគត់ដែលមានលេខ ១ខ្ទង់ និងចំនួនគត់ដែលមានលេខ ១ខ្ទង់។ សិស្សផ្សេងទៀតអាចមានសមត្ថភាពរាប់សំណុំនៃវត្ថុ ឬអាចស្គាល់ចំនួន។ |



# ផ្នែកទី២៖ លទ្ធផលសិក្សារបស់សិស្ស

១. លទ្ធផលអំណាន និងគណិតវិទ្យា

២. ការវិភាគកត្តាពាក់ព័ន្ធ



# ១. លទ្ធផលអំណាន និងគណិតវិទ្យា

# លទ្ធផលអំណាន តាមប្រទេសនីមួយៗ SEA-PLM 2024




ពិន្ទុមធ្យមអំណានរបស់អាស៊ាននៅក្នុង SEA-PLM ឆ្នាំ២០២៤ គឺ៣០០ ពិន្ទុ។ ពិន្ទុអំណានរបស់កម្ពុជាស្ថិតនៅលំដាប់ទីបួនក្នុងចំណោមប្រទេសទាំងប្រាំមួយ ដោយមានការកើនឡើង ៦ពិន្ទុ (ពី២៩០ ដល់ ២៩៦) ចំណែកឯវៀតណាម និងម៉ាឡេស៊ី មានការថយចុះ។



# លទ្ធផលអំណាន តាមកម្រិតសមត្ថភាពនីមួយៗ ឆ្នាំ២០១៩ និងឆ្នាំ២០២៤




- ភាគរយសិស្សថ្នាក់ទី៥ កម្ពុជាដែលមានសមត្ថភាពខ្ពស់ (ចាប់ពីកម្រិត៥ និងខ្ពស់ជាងនេះ) បានកើនពី ២៧% ក្នុងឆ្នាំ២០១៩ ដល់ ៣៩% ក្នុងឆ្នាំ២០២៤
- ភាគរយសិស្សសម្រេចបានលទ្ធផលខ្ពស់ជាងគេកម្រិតទី៦ បានកើនឡើងពី១១% (ឆ្នាំ២០១៩) ដល់ ១៨% (ឆ្នាំ២០២៤) ទោះបីជាសិស្សទាំងនោះរៀននៅថ្នាក់ទី៥ ក៏ដោយ
- ភាគរយសិស្សដែលមិនអាចអានអត្ថបទសាមញ្ញៗ (កម្រិត៣ និងទាបជាងនេះ) បានថយចុះពី ៤៧% ក្នុងឆ្នាំ២០១៩ មក ៣៧% ក្នុងឆ្នាំ២០២៤។



# លទ្ធផលគណិតវិទ្យា តាមប្រទេសនីមួយៗ SEA-PLM 2024




ពិន្ទុមធ្យមគណិតវិទ្យារបស់សិស្សថ្នាក់ទី៥ បានកើនឡើងពី ២៨៩ ពិន្ទុ ក្នុងឆ្នាំ២០១៩ ដល់ ៣០១ ពិន្ទុ ក្នុងឆ្នាំ ២០២៤ ខ្ពស់ជាងប្រទេសពីរផ្សេងទៀត (ឡាវ និងហ្វីលីពីន) ប៉ុន្តែទាបជាងមធ្យមភាគរបស់ប្រទេសបីផ្សេងទៀត។

SEA-PLM



# លទ្ធផលគណិតវិទ្យា តាមកម្រិតសមត្ថភាពនីមួយៗឆ្នាំ២០១៩ និង២០២៤




- ភាគរយសិស្សមានសមត្ថភាពខ្ពស់ (ពីកម្រិត៥ ឡើង) បានកើនពី៣៩% ក្នុងឆ្នាំ២០១៩ ដល់ ៦២% ឆ្នាំ២០២៤
- ភាគរយសិស្សដែលសម្រេចបានលទ្ធផលខ្ពស់ (កម្រិត៦ ឡើង) បានកើនពី ១៩% ដល់ ៤០%
- ភាគរយសិស្សដែលមានសមត្ថភាពទាប ដែលអាចយល់បានត្រឹមចំនួនទសភាគ និងអានរង្វាស់ជាប្រវែង និងទម្ងន់ (កម្រិត ៣ ចុះ) បានថយចុះពី ៣៦% ក្នុងឆ្នាំ២០១៩ មកដល់ ២០% ក្នុងឆ្នាំ២០២៤។



# ២. ការវិភាគកត្តាពាក់ព័ន្ធ

# លទ្ធផល តាមភេទសិស្ស នៅឆ្នាំ២០១៩ និង២០២៤




- សិស្សស្រីមានលទ្ធផលល្អជាងសិស្សប្រុសទាំងពីរមុខវិជ្ជា
- ចំពោះអំណាន សិស្សស្រីមានលទ្ធផលខ្ពស់ជាងសិស្សប្រុស (៩ ពិន្ទុ) នៅឆ្នាំ២០២៤។



# លទ្ធផល តាមប្រភេទការគ្រប់គ្រងសាលារៀន នៅឆ្នាំ២០១៩ និង២០២៤




- សិស្សមកពីសាលារៀនឯកជនទទួលបានពិន្ទុខ្ពស់ជាង សិស្សមកពីសាលារដ្ឋ ទាំងពីរមុខវិជ្ជា និងទាំងពីរវដ្ត
- គម្លាតពិន្ទុរវាងសាលារដ្ឋ និងសាលាឯកជនបានកាត់បន្ថយនៅឆ្នាំ២០២៤ បើប្រៀបធៀបទៅនឹងឆ្នាំ២០១៩

# លទ្ធផល តាមទីតាំងសាលារៀន នៅឆ្នាំ២០១៩ និង២០២៤




គម្លាតពិន្ទុរវាងសាលារៀននៅតំបន់ប្រជុំជន និងជនបទត្រូវបានកាត់បន្ថយនៅក្នុងឆ្នាំ២០២៤ បើប្រៀបធៀបនឹងឆ្នាំ២០១៩។



# លទ្ធផល តាមទីតាំងភូមិសាស្ត្រសាលារៀន នៅឆ្នាំ២០១៩ និង២០២៤




លទ្ធផលរបស់សិស្សថ្នាក់ទី៥ តាមទីតាំងភូមិសាស្ត្រនីមួយៗ និងមុខវិជ្ជាទាំងពីរ ក្នុងឆ្នាំ២០២៤ បានកើនឡើងបើប្រៀបធៀបទៅនឹងឆ្នាំ២០១៩។

SEA-PLM



# លទ្ធផល តាមកម្រិតស្ថានភាពសេដ្ឋកិច្ច-សង្គម នៅឆ្នាំ២០១៩ និង២០២៤




លទ្ធផលរបស់សិស្សមកពីគ្រួសារក្រីក្រ ទាំងពីរមុខវិជ្ជាកើនឡើង បើធៀបនឹងឆ្នាំ២០១៩ និង២០២៤ ប៉ុន្តែគម្លាត រវាងលទ្ធផលរវាងសិស្សមកពីគ្រួសារក្រីក្រ និងធូរធារនៅតែមានទំហំធំ។



# ផ្នែកទី៣៖
# កត្តាសំខាន់ៗរួមចំណែកដល់លទ្ធផលសិក្សារបស់សិស្ស

១. កត្តាសិស្ស
២. កត្តាគ្រូបង្រៀន
៣. កត្តាថ្នាក់រៀន
៤. កត្តាសាលារៀន
៥. កត្តាការចូលរួមរបស់សហគមន៍



# ១. កត្តាសិស្ស



# លទ្ធផលអំណាន និងគណិតវិទ្យាតាមក្រុមអាយុ នៅឆ្នាំ២០១៩ និង២០២៤







- រវាងឆ្នាំ២០១៩ និង ២០២៤ ភាគរយសិស្សដែលមានអាយុលើសបានថយចុះ
- សិស្សគ្រប់អាយុទទួលបានពិន្ទុខ្ពស់ជាងសិស្សលើសអាយុ ៨ពិន្ទុ ទាំងអំណាន និងគណិតវិទ្យា។



# លទ្ធផលអំណាន និងគណិតវិទ្យា តាមស្ថានភាពចូលរៀន ថ្នាក់មត្តេយ្យ នៅឆ្នាំ២០១៩ និង២០២៤







- រវាងឆ្នាំ២០១៩ និង ២០២៤ ភាគរយសិស្សដែលចូលរៀនថ្នាក់មត្តេយ្យមានរយៈពេល ១ឆ្នាំ ឬច្រើនជាងនេះ បានកើនឡើងពី ៥៨% ដល់ ៨០%
- សិស្សដែលបានចូលរៀនថ្នាក់មត្តេយ្យ មានលទ្ធផលល្អប្រសើរជាងសិស្សមិនបានចូលរៀន ទាំងអំណាន និងគណិតវិទ្យា។

SEA-PLM

# លទ្ធផលអំណាន និងគណិតវិទ្យា តាមស្ថានភាពនៃការរៀនត្រួតថ្នាក់ នៅឆ្នាំ២០២៤









- សិស្សកម្ពុជា ៣៧.៣% បានរៀនត្រួតថ្នាក់យ៉ាងតិចមួយកម្រិតថ្នាក់
- សិស្សដែលមិនធ្លាប់រៀនត្រួតថ្នាក់ រៀនពូកែជាងសិស្សដែលធ្លាប់រៀនត្រួតថ្នាក់ លើអំណាន និងគណិតវិទ្យា។ ភាពខុសគ្នាគឺ ១២ ពិន្ទុ ចំពោះអំណាន និង ១១ ពិន្ទុ ចំពោះគណិតវិទ្យា។ ការរៀនត្រួតថ្នាក់នាំឱ្យមានលទ្ធផលទាប។



# ២. កត្តាគ្រូបង្រៀន

# លទ្ធផលអំណាន និងគណិតវិទ្យា តាមភេទរបស់គ្រូបង្រៀននៅឆ្នាំ២០២៤




សិស្សដែលរៀនជាមួយអ្នកគ្រូ រៀនពូកែជាងសិស្សដែលរៀនជាមួយលោកគ្រូ ទាំងអំណាន និងគណិតវិទ្យា ដោយមានភាពខុសគ្នាស្មើនឹង ៦ ពិន្ទុទាំងពីរមុខវិជ្ជា។

SEA-PLM

# លទ្ធផលអំណាន និងគណិតវិទ្យា តាមកម្រិតគុណវុឌ្ឍិរបស់គ្រូបង្រៀននៅឆ្នាំ២០២៤




សិស្សដែលបង្រៀនដោយគ្រូដែលមានសញ្ញាបត្របរិញ្ញាបត្រឡើង រៀនពូកែជាងសិស្សដែលបង្រៀនដោយគ្រូដែលមានការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ ឬទាបជាងនេះ។



# ភាគរយគ្រូបង្រៀនថ្នាក់ទី៥ ចូលរៀនប្រធានបទនីមួយៗក្នុងឆ្នាំ២០២៤




- គ្រូបង្រៀនបានលើកឡើងអំពីប្រធានបទដែលបានរៀនទាំងនៅក្នុងវគ្គបណ្តុះបណ្តាលគ្រូ និងវគ្គវិក្រឹតការ រួមមាន ការគ្រប់គ្រងថ្នាក់រៀន (៩០.២%), វិធីសាស្រ្តបង្រៀន/គរុកោសល្យ (៨៨.៧%), សំណេរ (៨៦.៩%), អំណាន (៨៦.៨%), គណិតវិទ្យា (៨៥.៧%) និងវាយតម្លៃការសិក្សារបស់សិស្ស (៨៥.៦%)។
- ទោះជាយ៉ាងណាក៏ដោយ គ្រូបង្រៀន ៥៧.៤% បានលើកឡើងថា មិនទទួលបានការបណ្តុះបណ្តាលលើផ្នែកបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT), ការអប់រំបរិយាបន្ន (៥២.៩%) និងការបង្រៀនតាមសមត្ថភាពសិស្ស (៣០.០%)។



# ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន ដែលរាយការណ៍ដោយនាយកសាលារៀន




នាយកសាលារៀន ៩៨.៩% បានវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន តាមរយៈការសង្កេតការបង្រៀន ៩៤.៦% តាមរយៈការវាយតម្លៃលើលទ្ធផលរបស់សិស្ស ៧៦.៤% តាមរយៈការសង្កេតថ្នាក់និទស្សន៍ និង ៥០.៣% តាមរយៈការសង្កេតពីក្រុមអធិការកិច្ចមន្ទីរ ឬពីក្រសួងអប់រំ។



# ៣. កត្តាថ្នាក់រៀន



# សកម្មភាពអំណានក្នុងថ្នាក់




គ្រូបង្រៀន៩៨.១% បានបង្រៀនផ្តោតលើការកំណត់សូរ និងពាក្យ ៩៨.០% លើអំណានស្ទាត់ ៩៧.១% លើការអានឮៗដោយប្រើសំនួនវោហារ និង ៨២.៣% ផ្តោតលើវិធីអានត្រួសៗ។

# សកម្មភាពអំណានក្នុងថ្នាក់រៀន




គ្រូបង្រៀន ៨៣.០% បានឱ្យសិស្សអានដោយស្ងៀមស្ងាត់ដោយខ្លួនឯង, ៧៧.៩% អានឮៗឱ្យគ្រូស្តាប់ និង ៦៦.៨% អានតាមគ្រូឮខ្លាំងៗ ជារៀងរាល់ថ្ងៃ ឬស្ទើររៀងរាល់ថ្ងៃ។

# សកម្មភាពអានយល់ន័យក្នុងថ្នាក់រៀន




គ្រូបង្រៀន ៨៣.៤% តែងតែពន្យល់ន័យនៃពាក្យពិបាក, ៦៩.៣% កំណត់គំនិតសំខាន់ៗនៅក្នុងអត្ថបទ, និង ៦៥.២% វាយតម្លៃគំនិតក្នុងអត្ថបទ ប្រចាំថ្ងៃ ឬស្ទើររៀងរាល់ថ្ងៃ។

# សកម្មភាពគណិតវិទ្យាក្នុងថ្នាក់រៀន




សិស្សភាគច្រើនរៀនគណិតវិទ្យា តាមរយៈការស្ដាប់គ្រូពន្យល់ក្នុងថ្នាក់ ទន្ទេញរូបមន្ត និងធ្វើលំហាត់លើក្រដាស។ ប៉ុន្តែសិស្សមិនសូវដោះស្រាយលំហាត់ជាក្រុម ឬលំហាត់ដែលលំបាកខ្លាំង។



# ៤. ភត្តាសាលារៀន



# សៀវភៅសិក្សាគោល




នាយកសាលារៀន ៩៣.៦% បានលើកឡើងថា សិស្សម្នាក់បានប្រើសៀវភៅសិក្សាគោលគណិតវិទ្យា១ក្បាល ចំណែក ៩៦.៤% លើកឡើងថាប្រើសៀវភៅសិក្សាភាសាខ្មែរ ១ក្បាលសម្រាប់សិស្សម្នាក់ៗ។

# បណ្ណាល័យ




លទ្ធផលបង្ហាញថា នាយកសាលារៀនចំនួន ៧៧.៥% បានលើកឡើងថា សាលារៀនមានបណ្ណាល័យ និង ២២.៥% គ្មានបណ្ណាល័យ។



# ការត្រួតពិនិត្យវត្តមានសិស្ស




នាយកសាលារៀនចំនួន ៩៦.៦% បានលើកឡើងថា សាលារៀនបានកត់ត្រាវត្តមានសិស្សប្រចាំថ្ងៃ និង ៤១.៦% នាយកសាលាបានត្រួតពិនិត្យអវត្តមានសិស្សដោយផ្ទាល់។

# ការត្រួតពិនិត្យសាលារៀន




នាយកសាលារៀន ៤៥% បានលើកឡើងថា គ្រូឧទ្ទេសបានចុះពិនិត្យតាមដាននៅសាលារៀន ៦៨% ក្រុមអធិការកិច្ចបានចុះអធិការកិច្ច និង ៧៥% អធិការ ឬអ្នកត្រួតពិនិត្យបានទៅពិនិត្យសាលារៀនយ៉ាងហោចណាស់ម្តងក្នុងរយៈពេលពីរឆ្នាំចុងក្រោយ។

SEA-PLM



# បញ្ហាសិស្សកើតមាននៅសាលារៀន




បញ្ហាសិស្សកើតមានឡើងនៅតាមសាលារៀនយ៉ាងហោចណាស់១ដង ក្នុងមួយខែ រួមមាន សិស្សមករៀនយឺត ការគ្រប់គ្រងថ្នាក់រៀន និងសណ្តាប់ធ្នាប់ក្នុងពេលប្រឡង និងសិស្សអវត្តមាន។



# បញ្ហាហេដ្ឋារចនាសម្ព័ន្ធទូទៅតាមសាលារៀន




- សិស្ស ៧១.៦% រៀននៅសាលារៀនដែលខ្វះខាតបរិក្ខារបច្ចេកវិទ្យាឌីជីថល ឬមិនគ្រប់គ្រាន់ កង្វះបន្ទប់រៀន ឬមិនគ្រប់គ្រាន់ (៤៤.២%) និងកង្វះគ្រូបង្រៀនដែលមានសមត្ថភាព (៣៥.២%)។
- សិស្ស ៣១.៦% និង ២៣.២% រៀននៅសាលារៀនដែលមានបង្គន់មិនគ្រប់គ្រាន់ និងខ្វះខាតសម្ភារបង្រៀន។



# ៥. កត្តាការចូលរួមរបស់សហគមន៍

# ការចូលរួមរបស់ឪពុកម្ដាយចំពោះការសិក្សា




ការចូលរួមរបស់មាតាបិតាបានធ្វើឱ្យពិន្ទុកើន ១១ពិន្ទុ ផ្នែកអំណាន និង ១០ពិន្ទុ ផ្នែកគណិតវិទ្យា។

# ការចូលរួមរបស់ឪពុកម្ដាយចំពោះការសិក្សា




សិស្ស ៦០.៥% បាននិយាយថា ឪពុកម្ដាយបានជំរុញទឹកចិត្តពួកគេឱ្យទទួលបានជោគជ័យនៅសាលារៀនជារៀងរាល់ថ្ងៃ ឬស្ទើរតែរាល់ថ្ងៃ, ៤៤.២% ឪពុកម្ដាយរបស់ពួកគេតែងតែពិនិត្យមើលការធ្វើកិច្ចការផ្ទះ និង ៤២.៣% សួរពួកគេអំពីអ្វីដែលកំពុងរៀននៅសាលារៀន។

# ការចូលរួមរបស់សហគមន៍




នាយកសាលាបានលើកឡើងថា សហគមន៍បានចូលរួមថែទាំអគារសិក្សា ជួយរៃអង្គាសថវិកា និងជួយក្នុងថ្នាក់រៀន។



# ផ្នែកទី៤៖ ភាពជាពលរដ្ឋសកល

១. ការយល់ឃើញចំពោះការអប់រំភាពជាពលរដ្ឋសកល

២. ការយល់ឃើញ និងសមត្ថភាពរបស់គ្រូបង្រៀនទាក់ទងនឹងការអប់រំភាពជាពលរដ្ឋសកល



# ១. ការយល់ឃើញចំពោះការអប់រំភាពជាពលរដ្ឋសកល

# ការយល់ឃើញរបស់សិស្សអំពី ប្រធានបទ ភាពជាពលរដ្ឋសកល ដែលបានរៀននៅសាលារៀន




សិស្សកម្ពុជាភាគច្រើនបានរៀនសូត្រអំពីការការពារបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ សិស្សក្រោម ៥០% បានរៀនសូត្រអំពីការបំពុលបរិស្ថាន និងការស្គាល់ពីអ្នកដទៃ។



# ឥរិយាបថរបស់សិស្សអំពីបញ្ហាសង្គម




សិស្សកម្ពុជាភាគច្រើនមានឥរិយាបថវិជ្ជមានចំពោះបញ្ហាសង្គម ដូចជា ការចូលរួមក្នុងការការពារបរិស្ថាន យុត្តិធម៌ ការអប់រំ របៀបរស់នៅ និងការឱ្យតម្លៃមនុស្សជាតិ។



# ការព្រួយបារម្ភរបស់សិស្សចំពោះបញ្ហាទាក់ទងនឹងភាពជាពលរដ្ឋសកល




សិស្សកម្ពុជាភាគច្រើនមានការព្រួយបារម្ភអំពីបញ្ហាសកលដូចជា ការបាត់បង់ធនធានធម្មជាតិ ការប្រែប្រួលអាកាសធាតុ ការផុតពូជរុក្ខជាតិ និងការបំពុលបរិស្ថាន។

# អាកប្បកិរិយាជាពលរដ្ឋល្អ




សិស្សកម្ពុជាភាគច្រើនបានលើកឡើងថា ពួកគេធ្លាប់បានចូលរួមក្នុងសកម្មភាពកែលម្អបរិស្ថានសាលារៀន ការការពារបរិស្ថាន និងការហាមឃាត់ការបោះសំរាមផ្ដេសផ្ដាស។



# ២. ការយល់ឃើញ និងសមត្ថភាពរបស់គ្រូបង្រៀន ទាក់ទងនឹងការអប់រំភាពជាពលរដ្ឋសកល

# ឥរិយាបថរបស់គ្រូបង្រៀនចំពោះការរៀនភាពជាពលរដ្ឋសកលរបស់សិស្ស នៅសាលារៀន




គ្រូបង្រៀនភាគច្រើនយល់ឃើញថា ប្រធានបទដូចជា ការការពារបរិស្ថាន ការដោះស្រាយបញ្ហាដោយសន្តិវិធី ជាមួយ មិត្តរួមថ្នាក់ និងការដោះស្រាយបញ្ហានៅក្នុងសហគមន៍មានសារៈសំខាន់សម្រាប់សិស្ស។



# អាកប្បកិរិយារបស់គ្រូបង្រៀនអំពីបំណិន និងគុណតម្លៃនៃភាពជាពលរដ្ឋសកលរបស់សិស្ស




គ្រូបង្រៀនភាគច្រើនយល់ឃើញថា ការមានទំនាក់ទំនងជាមួយអ្នកដទៃ ការយល់ដឹងពីសមភាព ការមានឆន្ទៈប្រឆាំងនឹងភាពអយុត្តិធម៌ និងការចូលរួមដោះស្រាយបញ្ហាវិសមភាព គឺជាបំណិន និងគុណតម្លៃដ៏សំខាន់សម្រាប់សិស្សដែលត្រូវអភិវឌ្ឍខ្លួន។



# ការបណ្តុះបណ្តាលទាក់ទងនឹងភាពជាពលរដ្ឋសកល




គ្រូបង្រៀនបានលើកឡើងថា បានទទួលការ**បណ្តុះបណ្តាល** អំពីប្រធានបទទាក់ទងនឹងភាពជាពលរដ្ឋសកល រួមមាន៖ សិទ្ធិកុមារ ការការពារបរិស្ថាន ការអភិវឌ្ឍប្រកបដោយចីរភាព ជាដើម។

# ទំនុកចិត្តក្នុងការបង្រៀនប្រធានបទស្ដីពីភាពជាពលរដ្ឋសកល




គ្រូបង្រៀនបានលើកឡើងថា មានភាពជឿជាក់ក្នុងការបង្រៀនលើប្រធានបទភាពជាពលរដ្ឋសកល រួមមាន៖ សិទ្ធិកុមារ ការការពារបរិស្ថាន ការអភិវឌ្ឍប្រកបដោយចីរភាព ជាដើម។



# ផ្នែកទី៥៖ វិធានការលើកកម្ពស់មូលដ្ឋានគ្រឹះនៃការសិក្សា

១. សេចក្តីសង្ខេបអនុសាសន៍ដកស្រង់ពីរបាយការណ៍ថ្នាក់តំបន់

២. វិធានការចម្បងៗសម្រាប់ឆ្លើយតបនឹងលទ្ធផលវាយតម្លៃ SEA-PLM ឆ្នាំ២០២៤



# ១. សេចក្តីសង្ខេបអនុសាសន៍ដកស្រង់ពីរបាយការណ៍ថ្នាក់តំបន់

**អនុសាសន៍ ចំនួន១០ ក្នុងកម្មវិធីផ្សព្វផ្សាយរបាយការណ៍ថ្នាក់តំបន់ផ្លូវការ (នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥) រួមមាន៖**

1. បង្កើនការវិនិយោគលើមូលដ្ឋានគ្រឹះនៃការសិក្សា ដោយផ្តល់អាទិភាពដល់សិស្ស និងសាលារៀន ដែលងាយរងគ្រោះបំផុត
2. បន្តវិនិយោគលើការកសាងប្រព័ន្ធអប់រំដែលមានភាពធន់ដើម្បីជួយសិស្ស និងសាលារៀនឱ្យអាចប្រឈមមុខនឹងផលប៉ះពាល់ផ្សេងៗ
3. រៀបចំយុទ្ធសាស្ត្រថ្នាក់ពន្លឿន និងផ្តល់ការគាំទ្រដល់សិស្សរៀនយឺត ដើម្បីលើកកម្ពស់លទ្ធផលសិក្សាឱ្យប្រសើរឡើង។
4. លើកកម្ពស់ការអប់រំបរិយាបន្ន និងឆ្លើយតបទៅនឹងយេនឌ័រ ដើម្បីធានាថាសិស្សទាំងអស់ទទួលបានការសិក្សាពេញលេញ។
5. ដោះស្រាយវិសមភាពអប់រំ ដែលកើតមានដោយសារស្ថានភាពសេដ្ឋកិច្ច-សង្គមខុសគ្នា និងការឈ្វេងយល់ពីកត្តាផ្សេងៗទៀតដែលជះឥទ្ធិពលលើការសិក្សារបស់សិស្ស។
6. ធានាសមធម៌ក្នុងការផ្តល់កិច្ចអន្តរាគមន៍ផ្នែកការអប់រំកុមារតូច ការគាំទ្រគ្រូបង្រៀន និងការរៀបចំបរិយាកាសរៀនសូត្រ
7. បន្ស៊ីគោលនយោបាយស្តីពីការប្រើប្រាស់ភាសាក្នុងការសិក្សា ឱ្យត្រូវគ្នានឹងភាសាដែលសិស្សប្រើប្រាស់ប្រចាំថ្ងៃនៅផ្ទះ។
8. ពង្រឹងគុណវុឌ្ឍិគ្រូបង្រៀនដោយផ្តោតលើ វិធីសាស្ត្របង្រៀនផ្អែកតាមសមត្ថភាពសិស្សការបង្រៀនប្រកបដោយបរិយាបន្ន និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន (ICT)។
9. បង្កើនសមភាព និងប្រសិទ្ធភាពនៃការវិនិយោគលើវិស័យអប់រំដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាពតាមប្រទេសនីមួយៗ។
10. ប្រើប្រាស់ទិន្នន័យដើម្បីរៀបចំគោលនយោបាយ និងការពង្រឹងលើការត្រួតពិនិត្យវឌ្ឍនភាពនៃប្រព័ន្ធអប់រំ ដើម្បីធានាប្រសិទ្ធភាពនៃការវិនិយោគ។



# ២. វិធានការចម្បងៗសម្រាប់ឆ្លើយតបនឹងលទ្ធផល រង្វាយតម្លៃ SEA-PLM ឆ្នាំ២០២៤ របស់កម្ពុជា

## ១. កែលម្អការត្រៀមខ្លួនសិក្សារបស់កុមារ តាមរយៈការអប់រំកុមារតូច

1. ពង្រឹង និងពង្រីកការអប់រំកុមារតូចនៅតាមសហគមន៍ សហគ្រាស និងគ្រឹះស្ថានសាធារណៈ និងឯកជន
2. បន្តផ្តល់ឱកាសដល់កុមារឱ្យបានបញ្ចប់ថ្នាក់មត្តេយ្យសិក្សា មុនពេលចូលរៀននៅកម្រិតបឋមសិក្សា
3. ផ្តល់ការបណ្តុះបណ្តាលសមត្ថភាពដល់គ្រូបង្រៀនកម្រិតមត្តេយ្យសិក្សា និងអ្នកជំនាញអប់រំកុមារស្តីអំពីជំនាញបង្រៀន និងថែទាំកុមារផ្អែកលើល្បែងសិក្សា។

## ២. កែលម្អការសិក្សាមូលដ្ឋានគ្រឹះ តាមរយៈអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង

1. ពង្រីកការអនុវត្តកញ្ចប់សិក្សាថ្នាក់ដំបូងទូទាំងប្រទេស តាមរយៈការផ្តល់កញ្ចប់សម្ភារថ្នាក់ដំបូង (EGL) ដល់គ្រូបឋមសិក្សាទាំងអស់
2. ពង្រឹងវិធីសាស្ត្របង្រៀនលើផ្នែកអំណាន និងគណិតវិទ្យា
3. ពង្រឹងសកម្មភាពបណ្ណាល័យ និងលើកកម្ពស់ការអាននៅក្នុងបណ្ណាល័យ
4. រៀបចំការប្រកួតអំណាននៅកម្រិតសាលារៀន
5. ពង្រឹងការអនុវត្តកម្មវិធីសិក្សាតាមថ្នាលបឋម (PLP) សម្រាប់គ្រូបង្រៀន និងសិស្សក្នុងការបង្រៀន ការរៀន និងតេស្តរង្វាយតម្លៃ
6. ពង្រីកការអនុវត្តកម្មវិធីបង្រៀនសម្របសមត្ថភាពសិស្សរៀនយឺត (Personalized Teaching to Overcome Marginalization [PTOM]) ដើម្បីធានាថាសិស្សរៀនត្រូវនឹងកម្រិតថ្នាក់ កាត់បន្ថយអត្រាត្រួតថ្នាក់ ការបោះបង់ការសិក្សា និងបង្កើនអត្រាបញ្ចប់កម្រិតបឋមសិក្សា



# វិធានការចម្បងៗសម្រាប់ឆ្លើយតបនឹងលទ្ធផលវាយតម្លៃ SEA-PLM ឆ្នាំ២០២៤ របស់កម្ពុជា

## ៣. កែលម្អការអភិបាលកិច្ចសាលារៀននៅកម្រិតបឋមសិក្សា

1. អនុវត្តស្តង់ដាសាលារៀនគំរូ
2. ពង្រឹងប្រសិទ្ធភាពនៃដំណើរការអភិបាលកិច្ចសាលារៀន
3. ដោះស្រាយបញ្ហាលើសនិងខ្វះគ្រូបង្រៀន
4. បង្កើនការចូលរួមរបស់សហគមន៍
5. ពង្រឹងការធ្វើអធិការកិច្ចសាលារៀន
6. គាំទ្រសាលារៀនដោយពង្រឹងការគ្រប់គ្រងតាមសាលារៀន

## ៤. កែលម្អកម្មវិធីសិក្សាសាលារៀន និងម៉ោងបង្រៀន

1. បង្កើត និងអនុវត្តយុទ្ធសាស្ត្រកម្មវិធីសិក្សាបង្រៀនពេញមួយថ្ងៃ
2. បង្កើនម៉ោងសិក្សាលើមុខវិជ្ជាសំខាន់ៗ
3. ធានាគុណភាពម៉ោងសិក្សា
4. ពិនិត្យឡើងវិញនូវសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់
5. បញ្ចូលសកម្មភាពសិក្សានិងសំណួរតេស្តផ្អែកលើបញ្ញត្តិ និងការអភិវឌ្ឍសមត្ថភាពរបស់សិស្ស
6. រៀបចំថ្នាក់រៀនឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសាលារៀន



# វិធានការចម្បងៗសម្រាប់ឆ្លើយតបនឹងលទ្ធផលវាយតម្លៃ SEA-PLM ឆ្នាំ២០២៤ របស់កម្ពុជា

## ៥. ពង្រឹងសមត្ថភាពគ្រូបង្រៀន និងការអនុវត្តការបង្រៀន

1. ទាក់ទាញបន្ថែមនូវបេក្ខជនប្រឡងចូលធ្វើគ្រូបង្រៀនដែលមានសមត្ថភាព
2. បញ្ចូលកញ្ចប់សិក្សាថ្នាក់ដំបូងទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន
3. ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)
4. បន្តអនុវត្តការជ្រើសរើសគ្រូបង្រៀនផ្អែកលើកិច្ចព្រមព្រៀងការងារ
5. កែលម្អវិធីសាស្ត្របង្រៀនដោយប្រើវិធីសាស្ត្របង្រៀនថ្មីៗ
6. លើកទឹកចិត្តគ្រូបង្រៀនឱ្យប្រើធនធានបច្ចេកវិទ្យាឌីជីថល

## ៦. កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងបរិក្ខារសាលារៀន

1. សាងសង់បន្ទប់រៀនបន្ថែម
2. សាងសង់សាលាមត្តេយ្យក្នុងសាលាបឋមសិក្សាបន្ថែម
3. បំពាក់សម្ភារបង្រៀន និងរៀន ICT ដល់សាលារៀនដើម្បីលើកកម្ពស់ការអប់រំបច្ចេកវិទ្យាឌីជីថល
4. សាងសង់បណ្ណាល័យ និងប្រែក្លាយទៅជាបណ្ណាល័យអេឡិចត្រូនិក។



# វិធានការចម្បងៗសម្រាប់ឆ្លើយតបនឹងលទ្ធផលវាយតម្លៃ SEA-PLM ឆ្នាំ២០២៤ របស់កម្ពុជា

## ៧. លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភនៅតាមសាលារៀន

1. អនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន ផ្តល់អាហារូបករណ៍ លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភដល់សិស្សនៅបឋមសិក្សា
2. កែលម្អហេដ្ឋារចនាសម្ព័ន្ធសុខភាព រៀបចំបន្ទប់សុខភាពដែលមានស្តង់ដា លើកកម្ពស់បរិស្ថានសាលារៀនបៃតង និងគ្មានសំរាម
3. លើកកម្ពស់ការប្រើប្រាស់ទឹកស្អាត និងការថែរក្សាអនាម័យ
4. លើកកម្ពស់អាហារូបត្ថម្ភដោយផ្តោតលើសុវត្ថិភាពចំណីអាហារ និងការផ្តល់អាហារនៅសាលារៀន
5. បញ្ចូលការអប់រំសុខភាពក្នុងកម្មវិធីសិក្សា

# សូមអរគុណ !






